# **ក្រសួងអប់រំ យុវជន និងកីឡា**

សូមជូនដំណឹងដល់សាធារណជនទាំងពីរភេទថា ក្នុងឆ្នាំសិក្សា ២០០៨-២០០៩ ក្រសួងអប់រំយុវជន និងកីឡា នឹងធ្វើការជ្រើសរើសនិស្សិតអាហារូបករណ៍ថ្នាក់ក្រោមឧត្តមសិក្សា និងប្រលងជ្រើសរើសនិស្សិតអាហារូបករណ៍ ថ្នាក់ឧត្តមសិក្សាទៅសិក្សានៅសាធារណរដ្ឋសង្គមនិយមវៀតណាមចំនួន ១០០ កន្លែងដែលមាន បែងចែកដូច ខាងក្រោម:

I.**ថ្នាក់ក្រោមឧត្តមសិក្សា : ថ្នាក់អនុបណ្ឌិត និងបណ្ឌិត** ( Ph-D) ( **៣០ កន្លែង** )

ការជ្រើសរើសនិងបែងចែងជាពីរដំណាក់កាលដូចខាងក្រោម:

១-ដំណាក់កាលទី១សំរាប់និស្សិត-មន្ត្រីរាជការ ដែលបានបញ្ចប់ការសិក្សាមកពីស.ស.វៀតណាម មានសញ្ញាប័ត្រមុនឆ្នាំ២០០៨ ចំនួន ១៥នាក់។

២-ដំណាក់កាលទី២ សំរាប់និស្សិត-មន្ត្រីរាជការ ដែលបានបញ្ចប់ការសិក្សាមកពី ស.សវៀតណាម មានសញ្ញាប័ត្រក្នុងឆ្នាំ២០០៨ ចំនួន ១៥ នាក់

**ក-លក្ខខណ្ឌនៃការជ្រើសរើស**

បេក្ខជនទាំងពីរភេទត្រូវ :

-មានសញ្ជាតិកម្ពុជា

-ជាអតីតនិស្សិតមកពី ស.សវៀតណាម

-អាយុមិនលើសពី ៤០ ឆ្នាំ គិតត្រឹម ខែតុលា ឆ្នាំ ២០០៨

-មានសញ្ញាប័ត្រឧត្តមសិក្សាសំរាប់ថ្នាក់អនុបណ្ឌិត និងសញ្ញាប័ត្រអនុបណ្ឌិតសំរាប់ថ្នាក់បណ្ឌិត

-មានសុខភាពល្អ បរិបូរណ៍ទាំងកាយសម្បទា និងសតិបញ្ញា

**ខ. សំណុំឯកសារត្រូវបំពេញ**

| | | |
|---|---|---|
| ១-ពាក្យសុំអាហារូបករណ៍ | ០១ ច្បាប់ | "មានគំរូ" |
| ២-ជីវប្រវត្តិសង្ខេប | ០២ ច្បាប់ | "មានគំរូ" |
| ៣-កិច្ចសន្យា | ០១ច្បាប់ | "មានគំរូ" |

៤-សញ្ញាប័ត្រទទួលបាន( ជាភាសាវៀតណាម ឬ ភាសាអង់គ្លេស)

៥-រូបថត ៤ គុណ ៦ ( ពណ៌ធម្មជាតិទើបថតថ្មី) ០២ សន្លឹក

៦-លិខិតឧទ្ទេសនាមពីថ្នាក់ក្រសួង "ចំពោះបេក្ខជន ជាមន្ត្រីរាជការ"

៧-វិញ្ញាបនប័ត្រសម្បទា "០២ សន្លឹក" បំពេញក្រោយពេលដែលសាមីជន ត្រូវបានជ្រើសរើសរួច។

គ-**ការជ្រើសរើស**

ក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំគណៈកម្មការ ដើម្បីធ្វើការជ្រើសរើសបេក្ខជនតាមការជាក់ស្តែង។

**ឃ-កាលបរិច្ឆេទ និង ទីកន្លែងទទួលពាក្យ**

-ដំណាក់កាលទី១ ចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ **ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨**

-ដំណាក់កាលទី២ ចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ **ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៨**

**II-ថ្នាក់ឧត្តមសិក្សា (៧០ កន្លែង)**

មុខវិជ្ជាសិក្សាមានគ្រប់ផ្នែក ដែលក្រសួង នឹងជូនដំណឹងនៅពេលក្រោយ។

**១-លក្ខខណ្ឌនៃការប្រឡងជ្រើសរើសៈ**

បេក្ខជនទាំងពីរភេទត្រូវៈ

- មានសញ្ជាតិកម្ពុជា
- មានអាយុមិនលើសពី ៣៥ឆ្នាំ គិតត្រឹមខែតុលា ឆ្នាំ២០០៨
- មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាប័ត្រមានតំលៃស្មើ
- មានសុខភាពល្អ បរិបូរណ៍ទាំងកាយសម្បទា និងសតិបញ្ញា

**២-កាលបរិច្ឆេទ និង ទីកន្លែងទទួលពាក្យ**

ចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់**ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៨ វេលាម៉ោង ១៦ ម៉ោ** ០០ នៅការិយាល័យអាហារូបករណ៍ និងកម្មសិក្សានៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ អាស័យ ដ្ឋានអគារលេខ២៣ ផ្លូវ៣៦០ សង្កាត់បឹងកេងកង១ ខ័ណ្ឌចំការមន (**ខាងកើតស្ថានីយ៍ទូរទស្សន៍អប្សរាប្រហែល ៥០ម៉ែត្រ**)។

**៣-កាលបរិច្ឆេទប្រឡង**

-ប្រឡងនៅ **ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៨**។ (មណ្ឌលប្រឡង នឹងជំរាបជូននៅ ពេលក្រោយ)។

**៤-វិញ្ញាសាប្រឡងមាន**

| | |
|---|---|
| -វប្បធម៌ទូទៅ | រយៈពេល ១ ម៉ោង ៣០ នាទី |
| -រូបវិទ្យា | រយៈពេល ១ ម៉ោង |
| -គីមីវិទ្យា | រយៈពេល ១ ម៉ោង |
| -គណិតវិទ្យា | រយៈពេល ១ ម៉ោង ៣០ នាទី |

**៥-<u>សំណុំឯកសារដែលត្រូវបំពេញ និងជូនភ្ជាប់មាន៖</u>**

១-ពាក្យសុំអាហារូបករណ៍ ០១ ច្បាប់ "មានគំរូ"

២-ជីវប្រវត្តិសង្ខេប ០២ ច្បាប់ "មានគំរូ"

៣-កិច្ចសន្យា ០១ច្បាប់ "មានគំរូ"

៤-សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាប័ត្រមានតំលៃស្មើ (ច្បាប់ថតចំលង ០១ ច្បាប់) (ភ្ជាប់ច្បាប់ដើម) ដើម្បីផ្ទៀងផ្ទាត់

៥-រូបថត ៤ គុណ ៦ ០២ សន្លឹក (ថតពីមុខ រូបថតថ្មី)

៦-លិខិតឧទ្ទេសនាមពីថ្នាក់ក្រសួង "ចំពោះបេក្ខជន ជាមន្ត្រីរាជការ"

៧-វិញ្ញាបនប័ត្រសម្បទា និង ជំងឺអេដស៍"០២ សន្លឹក" បំពេញក្រោយពេលសាមីជនប្រឡងជាប់ ។

ទន្ទឹមនឹងនេះក្រសួងអប់រំ យុវជន និងកីឡា នឹងទទួលយកសិស្សមួយចំនួនឱ្យទៅសិក្សាថ្នាក់ឧត្តមសិក្សាជាលក្ខណៈឯកជននៅសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងឆ្នាំសិក្សា២០០៨-២០០៩ នេះផងដែរ ។ កាលបរិច្ឆេទនៃការឈប់ទទួលពាក្យនៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០០៨

ចំពោះពត៌មានលំអិតផ្សេងៗ សូមអញ្ជើញទាក់ទងជាមួយការិយាល័យអាហារូបករណ៍ និងកម្មសិក្សានៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអហារូបករណ៍ អាស័យដ្ឋានអគារលេខ២៣ ផ្លូវ ៣៦០ សង្កាត់បឹងកេងកង១ ខ័ណ្ឌចំការមន (**ខាងកើតស្ថានីយ៍ទូរទស្សន៍អប្សរាប្រហែល ៥០ម៉ែត្រ**) ។